គតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

ចែកចាយ ៖ ទូទៅ
១៨ ឧសភា ២០២២

ភាសាដើម ៖ អង់គ្លេស

## គណៈកម្មាធិការសិទ្ធិមនុស្ស

## សេចក្តីសង្កេតសន្និដ្ឋានទៅលើរបាយការណ៍តាមកាលកំណត់លើកទី៣របស់កម្ពុជា

១. គណៈកម្មាធិការបានធ្វើការពិនិត្យទៅលើរបាយការណ៍តាមកាលកំណត់លើកទី៣របស់កម្ពុជា[1] លើកទី៣៨៥០ លើកទី៣៨៥២ និងលើកទី៣៨៥៤[2] ដែលបានធ្វើឡើងនៅថ្ងៃទី៩ ទី១០ និងទី១១ ខែមីនា ឆ្នាំ២០២២។ កិច្ចប្រជុំបានធ្វើឡើងក្នុងទម្រង់បត់បែន ដោយសារការរាតត្បាតនៃមេរោគកូរ៉ូណា (កូវីដ១៩)។ នៅក្នុងកិច្ចប្រជុំលើកទី៣៨៦៨ និង៣៨៧០ ដែលបានធ្វើឡើងនៅថ្ងៃទី២២ និង២៣ ខែមីនា ឆ្នាំ២០២២ គណៈកម្មាធិការបានអនុម័តយកនូវសេចក្តីសង្កេតសន្និដ្ឋាន។

## ក. សេចក្តីផ្តើម

២. គណៈកម្មាធិការបានធ្វើការស្វាគមន៍ ចំពោះការដាក់ជូនរបាយការណ៍ដំណាក់កាលទីបីរបស់ព្រះរាជាណាចក្រកម្ពុជា និងព័ត៌មានដែលបានបង្ហាញជូននៅក្នុងរបាយការណ៍នេះ។ គណៈកម្មាធិការ បានបង្ហាញនូវការកោតសរសើរ ចំពោះឱកាសចូលរួមកិច្ចសន្ទនាក្នុងន័យស្ថាបនាជាមួយគណៈប្រតិភូជាន់ខ្ពស់នៃរដ្ឋភាគី ទៅលើវិធានការដែលបានធ្វើឡើងនៅអំឡុងពេលដែលរបាយការណ៍នេះត្រូវបានធ្វើឡើង ដើម្បីអនុវត្តបទប្បញ្ញត្តិនៃកតិកាសញ្ញា។ គណៈកម្មាធិការ ពិតជាអរគុណចំពោះរដ្ឋភាគី ចំពោះការឆ្លើយតបជាលាយលក្ខណ៍អក្សរ[3] ទៅលើបញ្ជីបញ្ហាដែលបានលើកឡើង[4] ដែលនេះជាឯកសារជំនួយបន្ថែមពីលើការឆ្លើយតបជាពាក្យសម្តីពីសំណាក់គណៈប្រតិភូ និងចំពោះការផ្តល់ព័ត៌មានបន្ថែមជាលាយលក្ខណ៍អក្សរ។

## ខ. ទិដ្ឋភាពវិជ្ជមាន

៣. គណៈកម្មាធិការស្វាគមន៍ចំពោះរដ្ឋភាគីក្នុងការទទួលយកមកអនុវត្តនូវវិធានការច្បាប់ គោលនយោបាយ និងស្ថាប័ន ដូចខាងក្រោមនេះ ៖

(ក) ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ និងគោលនយោបាយយុទ្ធសាស្ត្រ និងផែនការអនុវត្តយុត្តិធម៌អនីតិជន ឆ្នាំ២០១៨-២០២០

[1] CCPR/C/KHM/3
[2] CCPR/C/SR.3850, CCPR/C/SR.3852 និង CCPR/C/SR.3854
[3] CCPR/C/KHM/RQ/3
[4] CCPR/C/KHM/Q/3

(ខ) អនុក្រឹត្យលេខ១៥៥ ស្តីអំពីការរៀបចំ និងដំណើរការមជ្ឈមណ្ឌលយុវសារនីតិសម្បទា ចុះថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០១៧ សម្រាប់ការគ្រប់គ្រងអនីតិជន

(គ) ផែនការសកម្មភាពជាតិលើកទី៣ ស្តីអំពីការទប់ស្កាត់អំពើហិង្សាទៅលើស្ត្រី ឆ្នាំ២០១៩-២០២៣

(ឃ) ការបង្កើតឱ្យមានគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក ដោយយោងតាមព្រះរាជក្រឹត្យលេខ ០៨១៧/៦១៩ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៧

(ង) ផែនការយុទ្ធសាស្ត្រជាតិស្តីពីការកំណត់អត្តសញ្ញាណ ឆ្នាំ២០១៧-២០២៦ ដើម្បីធានាថាប្រជាពលរដ្ឋគ្រប់រូបទទួលបាននូវអត្តសញ្ញាណស្របច្បាប់

## គ. បញ្ហាចម្បងនៃការព្រួយបារម្ភ និងអនុសាសន៍

លទ្ធភាពសមស្របក្នុងការអនុវត្តកតិកាសញ្ញា

៤. ខណៈពេលដែលមានការកត់សម្គាល់ថារដ្ឋភាគី បានរៀបចំវគ្គបណ្តុះបណ្តាលជាបន្តបន្ទាប់ ស្តីអំពីសិទ្ធិមនុស្សជាសកល រួមបញ្ចូលទាំងកតិកាសញ្ញានេះ ទៅកាន់អង្គចៅក្រម និងមេធាវី គណៈកម្មាធិការនៅតែបន្តមានការព្រួយបារម្ភ អំពីកង្វះការអនុវត្តជាក់ស្តែងទាក់ទងនឹងសិទ្ធិទាំងឡាយដែលបានចែងក្នុងកតិកាសញ្ញានេះពីសំណាក់តុលាការ ក្នុងសេចក្តីសម្រេចរបស់ខ្លួន និងការកើតឡើងនូវចន្លោះប្រហោងនៃការការពារ។ គណៈកម្មាធិការពិតជាសោកស្តាយដែលរដ្ឋភាគីមិនទាន់បានផ្តល់សច្ចាប័នទៅលើ ពិធីសារបន្ថែមទីមួយ (the first Optional Protocol ) លើកតិកាសញ្ញាដែលអាចផ្តល់ឱកាសសម្រាប់ ការបញ្ជូនទំនាក់ទំនងជាលក្ខណៈបុគ្គល (មាត្រា២)។

**៥. រដ្ឋភាគីគួរតែបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនបន្ថែមទៀត ក្នុងការបង្កើនការយល់ដឹងស្តីអំពីកតិកាសញ្ញា របស់អង្គចៅក្រម ព្រះរាជអាជ្ញា មេធាវី និងសាធារណៈជន ឱ្យបានទូលំទូលាយ ដើម្បីធានាឱ្យបាននូវការអនុវត្តកតិកាសញ្ញានេះ នៅក្នុងតុលាការជាតិ។ រដ្ឋភាគីគួរតែផ្តល់សច្ចាប័នទៅលើពិធីសារបន្ថែមទីមួយ (the first Optional Protocol) លើកតិកាសញ្ញា ដែលអាចផ្តល់ឱកាសសម្រាប់ ការបញ្ជូនទំនាក់ទំនងជាលក្ខណៈបុគ្គល។**

ស្ថាប័នសិទ្ធិមនុស្សជាតិ

៦. គណៈកម្មាធិការបានកត់សម្គាល់ឃើញ នូវដំណើរការនៃការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិរបស់រដ្ឋភាគីតាមរយៈការរៀបចំសេចក្តីព្រាងច្បាប់ថ្មីនៅឆ្នាំ២០២១។ ក៏ប៉ុន្តែ គណៈកម្មាធិការនៅតែមានសេចក្តីព្រួយបារម្ភអំពីកង្វះសេចក្តីទុកចិត្ត ដែលបានលើកឡើងដោយសង្គមស៊ីវិល អ្នកការពារសិទ្ធិមនុស្ស និងសហជីពចំពោះការបង្កើតនូវស្ថាប័នសិទ្ធិមនុស្សជាតិ ដែលគួរឱ្យជឿជាក់ មានប្រសិទ្ធភាព និងឯករាជ្យ ដោយការខ្វះខាតនូវដំណើរការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ (មាត្រា២)។

**៧.  រំលឹកឡើងវិញនូវអនុសាសន៍លើកមុនរបស់គណៈកម្មាធិការ[5] រដ្ឋភាគីគួរតែជំរុញដំណើរការឈានទៅមុខមួយកម្រិតទៀត ក្នុងការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិ ដោយផ្អែកលើគោលការណ៍ស្តីពីឋានៈនៃស្ថាប័នជាតិដើម្បីសិទ្ធិមនុស្ស សម្រាប់ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស (គោលការណ៍ទីក្រុងប៉ារីស)។ រដ្ឋភាគីគួរតែរៀបចំដំណើរការពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ ប្រកបដោយភាពបើកចំហ តម្លាភាព និងមានអត្ថន័យជាមួយភាគីពាក់ព័ន្ធនានា រួមទាំងសង្គមស៊ីវិលដែរ។**

វិធានការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

៨.  បើទោះបីជាមានការអនុវត្តវិធានការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយក្តី ក៏គណៈកម្មាធិការនៅតែមានការព្រួយបារម្ភពីកង្វះខាតនីតិវិធីការពារក្នុងច្បាប់ស្តីអំពីការប្រឆាំងអំពើពុករលួយ ក៏ដូចជាការខ្វះខាតការអនុវត្តច្បាប់ដែលមានប្រសិទ្ធិភាព។ គណៈកម្មាធិការនៅតែបន្តព្រួយបារម្ភពីកង្វះខាតនៃឯករាជ្យភាព និងការស៊ើបអង្កេតដោយមានប្រសិទ្ធិភាព របស់អង្គភាពប្រឆាំងអំពើពុករលួយ និងទិន្នន័យរាយការណ៍ពីអំពើពុករលួយនៅមានកម្រិតទាប ឬតិចតួច ដែលជនល្មើសទទួលរងការពិន័យ ដែលក្នុងនោះភាពភ័យខ្លាចពីការសងសឹកជាមូលហេតុមួយផងដែរ។ គណៈកម្មាធិការក៏បានកត់សម្គាល់ដោយការព្រួយបារម្ភ ពីការរាយការណ៍អំពីអំពើពុករលួយទាក់ទងនឹងការចាប់យកដីធ្លី និងការឈ្លានពានកាប់បំផ្លាញតំបន់ព្រៃការពារ ក៏ដូចជាការកាប់ព្រៃឈើខុសច្បាប់ និងភាពមិនប្រក្រតីក្នុងការផ្តល់សម្បទានសម្រាប់គម្រោងអភិវឌ្ឍន៍។

**៩.  រដ្ឋភាគីគួរបន្ថែមកិច្ចខំប្រឹងប្រែងរបស់ខ្លួនក្នុងការទប់ស្កាត់ និងលុបបំបាត់អំពើពុករលួយ និងនិទណ្ឌភាពគ្រប់កម្រិត។ រដ្ឋភាគីគួរតែធានាថា គ្រប់ករណីនៃអំពើពុករលួយទាំងអស់ រួមទាំងករណីទាំងឡាយណាដែលទាក់ទងនឹងបញ្ហាដីធ្លី ការកាប់ព្រៃឈើខុសច្បាប់ និងកិច្ចសន្យាសម្រាប់គម្រោងអភិវឌ្ឍន៍ ត្រូវបានស៊ើបអង្កេតប្រកបដោយឯករាជ្យភាព និងច្បាស់លាស់ត្រឹមត្រូវ ព្រមទាំងដាក់ទោសចំពោះបុគ្គលទាំងឡាយដែលមានទំនួលខុសត្រូវលើបញ្ហានេះ ហើយជនរងគ្រោះត្រូវបានផ្តល់សំណងពេញលេញ។ រដ្ឋភាគីគួរធានាឱ្យបាននូវការការពារគ្រប់គ្រាន់សម្រាប់បុគ្គលរាយការណ៍ សាក្សី និងជនរងគ្រោះពីអំពើពុករលួយ រួមបញ្ចូលទាំងការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការបុគ្គលរាយការណ៍ និងសេចក្តីព្រាងច្បាប់ស្តីពីសាក្សី អ្នកជំនាញការ និងជនរងគ្រោះ ក្រោយពីបានរៀបចំកិច្ចពិគ្រោះយោបល់ ប្រកបដោយភាពបើកចំហ តម្លាភាព និងមានអត្ថន័យ ជាមួយសង្គមស៊ីវិល និងភាគីពាក់ព័ន្ធផ្សេងទៀត។**

ការគ្រប់គ្រងប្រទេសក្នុងភាពអាសន្ន

១០.  គណៈកម្មាធិការមានការព្រួយបារម្ភអំពីព័ត៌មានដែលទទួលបានអំពីអំណាច ដ៏មានឥទ្ធិពលរបស់ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដែលបានប្រកាសឱ្យប្រើ នៅខែមេសា ឆ្នាំ២០២០ បានផ្តល់សិទ្ធិយ៉ាងខ្លាំងឱ្យរដ្ឋាភិបាលក្នុងការរឹតត្បឹតសិទ្ធិសេរីភាពជាមូលដ្ឋានជាច្រើន។ នេះពិតជាបង្កឱ្យមានការព្រួយ

[5] CCPR/C/KHM/CO/2, កថាខណ្ឌទី៦.

បារម្ភជាខ្លាំងអំពីការប្រើប្រាស់ និងអនុវត្តច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ដែលបានប្រកាសឱ្យប្រើនៅខែមីនា ឆ្នាំ២០២១ ដែលបានកំណត់ទណ្ឌកម្មធ្ងន់ធ្ងរ ចំពោះករណីដែលមិនអនុលោមតាម ឈានទៅរកការរឹតត្បិតដោយមិនសមស្របលើសិទ្ធិសេរីភាពជាមូលដ្ឋាន ជាពិសេសនៅពេលដែលច្បាប់នេះត្រូវបានប្រើដើម្បីបំបែកការជួបប្រជុំដោយសន្តិវិធី។ គណៈកម្មាធិការសោកស្តាយចំពោះកង្វះខាតនៃការជជែកដេញដោល និងពិគ្រោះយោបល់ជាមួយនឹងសង្គមស៊ីវិល មុនការប្រកាសឱ្យប្រើច្បាប់ទាំងនេះ (មាត្រា៤)។

១១. រដ្ឋភាគីគួរពិនិត្យឡើងវិញ និងធ្វើវិសោធនកម្មច្បាប់ ស្តីអំពីស្ថានភាពអាសន្ន និងជំងឺកូវីដ-១៩ ដើម្បីធានាឱ្យបាននូវអនុលោមភាពរបស់ខ្លួននឹងតម្រូវការរបស់មាត្រាទី៤ នៃកតិកាសញ្ញានេះ ដូចបានបកស្រាយនៅក្នុងសេចក្តីពន្យល់ទូទៅរបស់គណៈកម្មាធិការលេខ ២៩ (ឆ្នាំ២០០១) ស្តីពីការចាកឆ្ងាយពីបទប្បញ្ញតិរបស់កតិកាសញ្ញាអំឡុងពេលស្ថានភាពអាសន្ន និងសេចក្តីថ្លែងការណ៍របស់គណៈកម្មាធិការស្តីពីការចាកឆ្ងាយពីបទប្បញ្ញត្តិដែលទាក់ទងនឹងការរាតត្បាតនៃជំងឺកូវីដ១៩[6]។ រដ្ឋភាគីគួរធានាឱ្យបានថា រាល់យន្តការទាំងអស់ដែលបានដាក់ឱ្យអនុវត្តដើម្បីការពារប្រជាជនក្នុងស្ថានភាពអាសន្ន រួមទាំងការរីករាលដាលនៃជំងឺឆ្លង ជាវិធានការបណ្តោះអាសន្ន សមាមាត្រ និងមានភាពចាំបាច់ពិតប្រាកដ ព្រមទាំងអាចត្រូវត្រួតពិនិត្យឡើងវិញបានដោយយន្តការយុត្តិធម៌។ រដ្ឋភាគីគួរតែធានាថា ការត្រួតពិនិត្យឡើងវិញ និងវិសោធនកម្មនៃច្បាប់ទាំងនេះ ត្រូវបានធ្វើឡើងដោយបើកចំហរ តម្លាភាព និងមានដំណើរការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយនឹងភាគីពាក់ព័ន្ធនានា រួមទាំងសង្គមស៊ីវិលផងដែរ។

## ការប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព និងការរំលោភសិទ្ធិមនុស្សកាលពីអតីតកាល

១២. គណៈកម្មាធិការសូមធ្វើការបញ្ជាក់ឡើងវិញពីក្តីបារម្ភ អំពីកង្វះខាតនៃដំណើរវិវត្តក្នុងការស៊ើបអង្កេត និងកាត់ទោសករណីរំលោភសិទ្ធិមនុស្សកាលពីអតីតកាល រួមទាំងការសម្លាប់ក្រៅប្រព័ន្ធតុលាការ និងការបាត់ខ្លួនដោយបង្ខំ ដែលបានកើតឡើងក្រោយពីការចុះសន្ធិសញ្ញាទីក្រុងប៉ារីស ឆ្នាំ១៩៩១។ គណៈកម្មាធិការក៏មានក្តីបារម្ភពីការខ្វះខាតសកម្មភាពរបស់រដ្ឋភាគី ដែលក្នុងនោះរួមមានតុលាការក្នុងស្រុក ក្នុងការឆ្លើយតបទៅនឹងការបញ្ចប់រឿងក្តីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយមិនមានការសិក្សាវាយតម្លៃពីគុណសម្បត្តិ ដែលអាចនឹងបន្សល់ទុកនូវសំណុំរឿងរំលោភសិទ្ធិមនុស្សពីអតីតកាល ដោយមិនបានដោះស្រាយ (មាត្រា២, ៦-៧ និង១៤)។

**១៣. គណៈកម្មាធិការបញ្ជាក់ឡើងវិញពីអនុសាសន៍ទាំងឡាយនាពេលកន្លងមក ពាក់ព័ន្ធនឹងនិទណ្ឌភាពចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ។[7] រដ្ឋភាគីគួរតែគោរពតាមកាតព្វកិច្ចរបស់ខ្លួនក្នុងការស៊ើបអង្កេតលើការរំលោភសិទ្ធិមនុស្សពីអតីតកាល ដែលបានកើតឡើងក្នុងរបប ប៉ុល ពត និងក្រោយពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស កាត់ទោសជនល្មើស ដោយដាក់ទោសពួកគេឱ្យសមាមាត្រនឹងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មទាំងនោះក្នុងពេលសមស្របណាមួយ និងផ្តល់ការជួសជុលពេញលេញ រួមទាំងសំណងគ្រប់គ្រាន់ដល់គ្រួសារជនរងគ្រោះ។**

---

[6] CCPR/C/128/2
[7] CCPR/C/KHM/CO/2 កថាខណ្ឌ១១

ការមិនរើសអើង

១៤. គណៈកម្មាធិការនៅតែមានកង្វល់អំពីការរើសអើង និងការផាត់ចេញជាប្រព័ន្ធ ដែលជនជាតិភាគតិចបានជួបប្រទះ ជាពិសេស ខ្មែរក្រោម និងជនជាតិខ្មែរដើមកំណើតវៀតណាម រួមមានការមិនផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណ ដែលនាំដល់ការរឹតត្បិតក្នុងការទទួលបានសិទ្ធិដទៃទៀតរបស់ពួកគេ។ គណៈកម្មាធិការក៏មានកង្វល់ផងដែរ អំពីការរើសអើង ការបែងចែក និងការមាក់ងាយដល់ជនមានពិការភាព ក៏ដូចជាក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ដែលជារឿយៗក៏រួមទាំងអំពើហិង្សា (មាត្រា២ និង ២៦)។

១៥. **រដ្ឋភាគីគួរតែ៖**

**(ក) អនុម័តច្បាប់ដែលគ្រប់ជ្រុងជ្រោយមួយហាមឃាត់ការរើសអើង រួមមានការរើសអើងតាមផ្នែកផ្សេងៗ ដោយផ្ទាល់ និងដោយប្រយោលនៅគ្រប់វិស័យ ទាំងសាធារណៈនិងឯកជន ដោយផ្អែកលើមូលដ្ឋានទាំងឡាយដែលបានហាមឃាត់នៅក្នុងកតិកាសញ្ញានេះ រួមមាន ជាតិសាសន៍ ពណ៌សម្បុរ ភេទ គំនិតនយោបាយ ឬគំនិតផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម និន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ ពិការភាព ឬស្ថានភាពដទៃទៀត ព្រមទាំងធានាការទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព និងសមស្របសម្រាប់ជនរងគ្រោះនៃការរើសអើង។**

**(ខ) ដាក់ចេញនូវវិធានការនានាប្រកបដោយប្រសិទ្ធភាព ដើម្បីប្រឆាំងនឹងការរើសអើង និងការផាត់ចេញប្រឆាំងនឹងជនជាតិភាគតិច ជាពិសេស ខ្មែរក្រោមនិងជនជាតិខ្មែរដើមកំណើតវៀតណាម រួមទាំងការធានាថាពួកគេទទួលបានឯកសារបញ្ជាក់អត្តសញ្ញាណ។**

**(គ) បង្ការការរើសអើង និងអំពើហិង្សាប្រឆាំងនឹងក្រុមអ្នកស្រឡាញ់ភេទដូចគ្នា និងជនមានពិការភាព រួមទាំងការរៀបចំយុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈ ដើម្បីប្រយុទ្ធប្រឆាំងនឹងការមាក់ងាយពីសង្គមទៅលើពួកគេ។**

សមតាពយេនឌ័រ

១៦. គណៈកម្មាធិការនៅតែមានកង្វល់អំពីការបន្តនៃនិយាមដែលមានលក្ខណៈរើសអើង និងផ្តត់គំនិតផ្នែកយេនឌ័រ ពាក់ព័ន្ធនឹងតួនាទីស្ត្រីក្នុងសង្គម។ គណៈកម្មាធិការក៏កត់សម្គាល់ជាមួយនឹងកង្វល់ផងដែរ អំពីចំនួនតំណាងស្ត្រីមានតិចតួច ដែលនៅតែបន្តមាននៅក្នុងតួនាទីជាអ្នកដឹកនាំ និងតួនាទីធ្វើសេចក្តីសម្រេចចិត្តនៅគ្រប់កម្រិតនៃជីវិតសាធារណៈ។ បន្ថែមលើនេះ គណៈកម្មាធិការក៏មានកង្វល់ថា ច្បាប់ការងារឆ្នាំ១៩៩៧ មិនបានបញ្ចូលគោលការណ៍ស្តីពីការទទួលបានប្រាក់ខែស្មើគ្នាសម្រាប់ការងារដែលមានតម្លៃស្មើគ្នា និងថាច្បាប់នេះមិនបានការពារអ្នកធ្វើការងារតាមផ្ទះ ដែលភាគច្រើនជាស្ត្រី (មាត្រា៣)។

១៧. **រដ្ឋភាគីគួរតែពង្រឹងវិធានការនានាដែលមានគោលបំណងធានាសមភាពយេនឌ័រ រួមមានតាមរយៈ៖**

(ក) ធានាថាច្បាប់និងគោលនយោបាយទាំងឡាយស្តីពីសមភាពយេនឌ័រ ត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាព និងពិនិត្យឡើងវិញលើច្បាប់ការងារ ឆ្នាំ១៩៩៧ ក្នុងគោលបំណងធានាការអនុវត្តគោលការណ៍ស្តីពីការទទួលបានប្រាក់ខែស្មើគ្នាសម្រាប់ការងារមានតម្លៃស្មើគ្នា ព្រមទាំងការធានានូវការការពារពេញលេញដល់អ្នកធ្វើការងារតាមផ្ទះ។

(ខ) លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីគោលការណ៍សមភាពរវាងស្ត្រីនិងបុរស និងតម្រូវការក្នុងការលុបបំបាត់ផ្នត់គំនិតផ្អែកយេនឌ័រ ព្រមទាំងធានាថាប្រព័ន្ធផ្សព្វផ្សាយទាំងឡាយលើកកម្ពស់រូបភាពវិជ្ជមានរបស់ស្ត្រី ក្នុងនាមជាអ្នកចូលរួមដ៏សកម្មក្នុងជីវិតសាធារណៈ និងនយោបាយ។

(គ) បង្កើនកិច្ចប្រឹងប្រែងរបស់ខ្លួន ដើម្បីធ្វើឱ្យសម្រេចឱ្យបាននូវការចូលរួមពេញលេញនិងស្មើភាពរបស់ស្ត្រីក្នុងជីវិតនយោបាយ និងសាធារណៈ ក្នុងរយៈពេលកំណត់ជាក់លាក់ រួមមានក្នុងរដ្ឋសភា តួនាទីតាមក្រសួង រាជធានី/ក្រុងតាមតំបន់ និងមូលដ្ឋាន និងតុលាការ ជាពិសេស ក្នុងតួនាទីធ្វើសេចក្តីសម្រេចចិត្ត។

អំពើហិង្សាប្រឆាំងនឹងនារីភេទ

១៨. ខណៈដែលគណៈកម្មាធិការកត់សម្គាល់លើកិច្ចប្រឹងប្រែងរបស់រដ្ឋភាគី ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាប្រឆាំងនឹងនារីភេទ គណៈកម្មាធិការនៅតែមានកង្វល់ចំពោះការពន្យារពេលក្នុងការពិភាក្សា និងការអនុម័តវិសោធនកម្មច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥ ដែលមានគម្លាត មួយចំនួនឈានទៅដល់ការធ្វើឱ្យជនទាំងឡាយដែលសិទ្ធិពួកគេត្រូវបានរំលោភ ក្លាយជាជនរងគ្រោះម្តងទៀត និងការរឹតត្បិតលើការទទួលបានយុត្តិធម៌។ គណៈកម្មាធិការក៏កត់សម្គាល់ជាមួយនឹងកង្វល់ផងដែរ អំពីភាពទូទៅនៃការអត់ឱនរបស់សង្គមចំពោះការប្រើអំពើហិង្សាប្រឆាំងនឹងនារីភេទ និងការអនុវត្តការបន្ទោសជនរងគ្រោះ។ គណៈកម្មាធិការសោកស្តាយដោយខ្វះព័ត៌មានអំពីចំនួនពាក្យបណ្តឹង ការចោទប្រកាន់ និងការផ្តន្ទាទោស ពាក់ព័ន្ធនឹងអំពើហិង្សាប្រឆាំងនឹងនារីភេទ (មាត្រា ២-៣, ៦-៧ និង ២៦)។

១៩. ដោយរំឭកឡើងវិញពីអនុសាសន៍របស់គណៈកម្មាធិការនាពេលកន្លងមក ស្តីពីអំពើហិង្សាផ្អែកលើយេនឌ័រ[8] រដ្ឋភាគីគួរតែចាត់វិធានការផ្សេងៗដើម្បីធានាថា ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥ ត្រូវបានពិនិត្យឡើងវិញ និងធ្វើវិសោធនកម្ម ដើម្បីផ្តល់និយមន័យ និងដាក់ទោសឱ្យបានគ្រប់ជ្រោយលើអំពើហិង្សាក្នុងគ្រួសារ ព្រមទាំងធានាការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព អនុលោមតាមកតិកាសញ្ញានេះ និងបទដ្ឋានអន្តរជាតិដទៃទៀត។ រដ្ឋភាគីគួរតែធានាផងដែរថា រាល់ករណីអំពើហិង្សាប្រឆាំងនឹងនារីភេទ ត្រូវបានស៊ើបអង្កេតយ៉ាងហ្មត់ចត់ ជនល្មើសត្រូវបានកាត់ទោស និងប្រសិនបើមានទោស ត្រូវដាក់ឱ្យសមាមាត្រ និងថាជនរងគ្រោះត្រូវទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព ទទួលបានការជួសជុលពេញលេញ រួមទាំងសំណងគ្រប់គ្រាន់ ព្រមទាំងទទួលបានការការពារ និងជំនួយគ្រប់គ្រាន់។ រដ្ឋភាគីគួរតែបន្តធ្វើយុទ្ធនាការលើកកម្ពស់ការយល់ដឹង ស្តីពីអំពើហិង្សាប្រឆាំងនឹងនារីភេទដល់សាធារណជន និងធានាថាអ្នកមានមុខងារផ្សេងៗនៅក្នុងប្រព័ន្ធច្បាប់ រួមមាន ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីអនុវត្តច្បាប់ ទទួលបានការបណ្តុះបណ្តាលពាក់ព័ន្ធនឹងបញ្ហានេះ។

[8] Ibid., para. 10.

## សិទ្ធិរស់រានមានជីវិត

២០. គណៈកម្មាធិការមានកង្វល់យ៉ាងខ្លាំងអំពីការចោទប្រកាន់ជាច្រើន និងធ្ងន់ធ្ងរ ពាក់ព័ន្ធទៅនឹងការសម្លាប់ក្រៅប្រព័ន្ធតុលាការ ដែលកើតមានលើថ្នាក់ដឹកនាំបក្សប្រឆាំង អ្នកការពារសិទ្ធិមនុស្ស អ្នកកាសែត និងសកម្មជនដីធ្លី នៅក្នុងរដ្ឋភាគី រួមទាំងការសម្លាប់សមាជិកគណបក្សប្រឆាំងម្នាក់ឈ្មោះ ស៊ិន ខុន ក្នុងខែវិច្ឆិកា ឆ្នាំ២០២១។ គណៈកម្មាធិការក៏មានកង្វល់ផងដែរអំពី កង្វះការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព និងមិនលំអៀងលើករណីសម្លាប់ទាំងនេះ ដែលនៅតែមិនទាន់បានដោះស្រាយនៅឡើយ (មាត្រា៦)។

២១. **ជាអាទិភាព រដ្ឋភាគីគួរតែធានាថារាល់ការចោទប្រកាន់ពីការសម្លាប់ក្រៅប្រព័ន្ធតុលាការ ត្រូវបានស៊ើបអង្កេតភ្លាមៗ ដោយមិនលំអៀង និងយ៉ាងហ្មត់ចត់។ ជនល្មើសទាំងអស់ ដោយមិនគិតពីតួនាទី ឬមុខតំណែងផ្លូវការ ត្រូវបានផ្តន្ទាទោស និងថាប្រសិនបើមានទោស ត្រូវដាក់ទោសឱ្យសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត។ រដ្ឋភាគីគួរតែចាត់រាល់វិធានការចាំបាច់ ដើម្បីបង្ការការសម្លាប់បែបនេះ កំណត់ស្វែងរកការពិត និងផ្តល់ការជួសជុលពេញលេញដល់គ្រួសារជនរងគ្រោះ។**

## ការហាមឃាត់អំពើទារុណកម្ម និងអំពើឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ឬទណ្ឌកម្មដទៃទៀត

២២. គណៈកម្មាធិការកត់សម្គាល់ជាមួយនឹងកង្វល់ថា ខណៈដែលមាត្រា ២១០ នៃក្រមព្រហ្មទណ្ឌហាមឃាត់អំពើទារុណកម្ម និងអំពើឃោរឃៅ តែបទប្បញ្ញត្តិនេះមិនបានចែងពីនិយមន័យផ្លូវច្បាប់មួយស្តីពីទារុណកម្ម និងការប្រព្រឹត្តមិនគប្បីនោះទេ។ គណៈកម្មាធិការក៏មានកង្វល់ផងដែរជុំវិញការចោទប្រកាន់នានាអំពីកង្វះឯករាជ្យភាព នៃគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម និងអំពើឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ឬទណ្ឌកម្មដទៃទៀត ក៏ដូចជា អំពីលទ្ធភាពមានកម្រិតរបស់គណៈកម្មាធិការនេះ ក្នុងការធ្វើទស្សនកិច្ចតាមពន្ធនាគារ និងសម្ភាសន៍ជនជាប់ឃុំ។ បន្ថែមលើនេះ គណៈកម្មាធិការមានកង្វល់យ៉ាងខ្លាំងអំពីការចោទប្រកាន់ពីអំពើទារុណកម្ម និងការប្រព្រឹត្តិមិនគប្បីដ៏ធ្ងន់ធ្ងរ ដែលកើតមាននៅក្នុងកន្លែងឃុំឃាំងរបស់នគរបាល និងកន្លែងឃុំឃាំងផ្សេងៗទៀត ដែលករណីខ្លះបានឈានទៅដល់ការបាត់បង់ជីវិត (មាត្រា៦-៧ និង ៩-១០)។

២៣. **រដ្ឋភាគីគួរតែចាត់វិធានការបន្ទាន់ និងរឹងមាំ ដើម្បីលុបបំបាត់អំពើទារុណកម្ម និងការប្រព្រឹត្តិមិនគប្បី រួមមានតាមរយៈ៖**

**(ក) កែសម្រួលច្បាប់នានាក្នុងគោលបំណងធានាថា ច្បាប់មានចែងអំពីនិយមន័យទារុណកម្ម ដែលស្របទាំងស្រុងទៅនឹងមាត្រា ១ នៃអនុសញ្ញាប្រឆាំងទារុណកម្ម អំពើឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ឬទណ្ឌកម្មដទៃទៀត និងមាត្រា ៧ នៃកតិកាសញ្ញានេះ។**

**(ខ) បង្កលក្ខណៈឱ្យគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម និងអំពើឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ឬទណ្ឌកម្មដទៃទៀត អាចអនុវត្តមុខងាររបស់ខ្លួនដោយឯករាជ្យ និងយ៉ាងមានប្រសិទ្ធភាព រួមទាំងការចុះទស្សនកិច្ចរាល់កន្លែងឃុំឃាំងជាទៀងទាត់ និងមិនចាំបាច់ជូនដំណឹងជាមុន។**

(គ) ធ្វើការស៊ើបអង្កេតភ្លាមៗ ដោយហ្មត់ចត់ ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងមិនលំអៀង រាល់ការចោទប្រកាន់ទាំងឡាយអំពីអំពើទារុណកម្ម និងការប្រព្រឹត្តិមិនគប្បី ស្របតាមគោលការណ៍ណែនាំសម្រាប់ការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព និងការចងក្រងឯកសារនៃអំពើទារុណកម្ម និងអំពើឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ឬទណ្ឌកម្មដទៃទៀត (ពិធីសារអ៊ីស្តង់ប៊ុល) ដោយធានាថា ជនល្មើសទាំងអស់ត្រូវបានកាត់ទោស ហើយប្រសិនបើមានទោស ត្រូវដាក់ទោសឱ្យបានសមស្រប និងថាជនរងគ្រោះទទួលបានការជួសជុលពេញលេញ។

(ឃ) ធានាការការពារដើមបណ្តឹងពីការសងសឹក និងធានាថាករណីនៃការសងសឹកណាមួយត្រូវបានស៊ើបអង្កេត និងជនល្មើសត្រូវបានកាត់ទោស ហើយប្រសិនបើមានទោស ត្រូវដាក់ទោសឱ្យបានសមស្រប។

លក្ខខណ្ឌនៃការឃុំខ្លួន

២៤. ខណៈដែលកត់សម្គាល់ពីកិច្ចប្រឹងប្រែងរបស់រដ្ឋភាគី ក្នុងការកាត់បន្ថយភាពចង្អៀតណែន និងកែលម្អលក្ខខណ្ឌនៅក្នុងកន្លែងឃុំខ្លួន គណៈកម្មាធិការនៅតែមានកង្វល់ចំពោះរបាយការណ៍ជាច្រើនដែលបង្ហាញថាចំនួនអ្នកជាប់ឃុំនៅក្នុងពន្ធនាគារបាន និងកំពុងកើនឡើងគួរឱ្យកត់សម្គាល់ ដែលជាមធ្យមពន្ធនាគារមួយផ្ទុកអ្នកជាប់ឃុំលើស ៣០០ ភាគរយ នៃសមត្ថភាពផ្ទុក។ គណៈកម្មាធិការក៏កត់សម្គាល់ជាមួយនឹងកង្វល់ផងដែរ ដែលអ្នកជាប់ឃុំជាច្រើនមិនទទួលបានអាហារ ទឹកស្អាត និងការព្យាបាលវេជ្ជសាស្ត្រគ្រប់គ្រាន់។ បន្ថែមលើនេះ គណៈកម្មាធិការក៏មានកង្វល់អំពីរបាយការណ៍នានាស្តីពីការរីករាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងពន្ធនាគារដែលចង្អៀតណែន ដោយអ្នកជាប់ឃុំមិនទទួលបានការព្យាបាលវេជ្ជសាស្ត្រ និងការធ្វើតេស្តឱ្យបានគ្រប់គ្រាន់ (មាត្រា ៧ និង ១០)។

២៥. រដ្ឋភាគីគួរតែបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីធានាថាលក្ខខណ្ឌនៃការឃុំឃាំង គឺអនុលោមតាមស្តង់ដារសិទ្ធិមនុស្សអន្តរជាតិដែលពាក់ព័ន្ធ រួមទាំងវិធានអង្គការសហប្រជាជាតិ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តិទៅលើជនជាប់ឃុំ (វិធាននែលសាន់ម៉ាន់ដឺឡា) ។ ជាពិសេសរដ្ឋភាគីគួរតែ ៖

(ក) កាត់បន្ថយនូវភាពចង្អៀតណែននៅក្នុងពន្ធនាគារឱ្យបានច្រើន ជាពិសេសតាមរយៈការអនុវត្តវិធានការមិនឃុំខ្លួនឱ្យកាន់តែទូលំទូលាយ ដែលជាជម្រើសជំនួសការជាប់ពន្ធនាគារ។

(ខ) ពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីកែលម្អលក្ខខណ្ឌនៃការឃុំឃាំង និងធានាឱ្យមានលទ្ធភាពទទួលបានអាហារ ទឹកស្អាត និងការថែទាំសុខភាពគ្រប់គ្រាន់សម្រាប់អ្នកជាប់ឃុំនៅគ្រប់ទីកន្លែងនៃការដកហូតសេរីភាព ជាពិសេសនៅកន្លែងឃុំឃាំងដែលមានការផ្ទុះឡើងនៃមេរោគកូវីដ-១៩។

សេរីភាព និងសុវត្ថិភាពរបស់មនុស្ស

២៦. គណៈកម្មាធិការមានការព្រួយបារម្ភអំពីចំនួនអ្នកដែលស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្នជាច្រើន រួមទាំងស្ត្រីដែលមានកូនតូចផងដែរ ដែលជារឿយៗត្រូវបានឃុំខ្លួនរួមជាមួយទណ្ឌិត។ គណៈកម្មាធិការក៏មានការព្រួយបារម្ភផងដែរ អំពីរបាយការណ៍ដែលថាការការពារផ្នែកច្បាប់ជាមូលដ្ឋានសម្រាប់ជនដែលត្រូវបានដកហូតសិទ្ធិសេរីភាព ជារឿយៗមិនត្រូវបានគោរព រួមទាំងសិទ្ធិទទួលបានព័ត៌មានអំពីការចោទប្រកាន់ប្រឆាំងនឹងពួកគេ

សិទ្ធិទទួលបានមេធាវី និងវេជ្ជបណ្ឌិតភ្លាមៗតាមជម្រើសរបស់ពួកគេ និងសិទ្ធិជូនដំណឹងដល់បុគ្គលម្នាក់តាមការជ្រើសរើសរបស់ពួកគេអំពីការឃុំខ្លួននេះ (មាត្រា ៩-១០ និង ១៤)។

២៧. រដ្ឋភាគីគួរតែចាត់វិធានការផ្លូវច្បាប់ និងវិធានការផ្សេងទៀតប្រកបដោយប្រសិទ្ធភាព ដើម្បីធានាថាការឃុំខ្លួនបណ្តោះអាសន្ននឹងអាចត្រូវបានប្រើជាវិធានការពិសេស និងមានពេលកំណត់ច្បាស់លាស់ ជាពិសេសចំពោះម្តាយដែលមានកូនតូច និងបង្កើនការប្រើប្រាស់វិធានការនានាជំនួសឱ្យការឃុំឃាំងបណ្តោះអាសន្ន។ រដ្ឋភាគីគួរតែធានាថា ការការពារផ្លូវច្បាប់ទាំងអស់ ត្រូវបានធានាក្នុងការអនុវត្តចំពោះបុគ្គលទាំងអស់ដែលត្រូវបានដកហូតសិទ្ធិសេរីភាពតាំងពីខណៈពេលដំបូងនៃការឃុំខ្លួន រួមទាំងតាមរយៈការអនុម័តជាផ្លូវការនូវសេចក្តីព្រាងគោលនយោបាយជំនួយផ្នែកច្បាប់ ដើម្បីធានាថាជំនួយផ្នែកច្បាប់មានសម្រាប់បុគ្គលទាំងអស់ដែលត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម។

ការចាប់ខ្លួន និងការឃុំខ្លួនដោយបំពាន

២៨. ខណៈដែលគណៈកម្មាធិការកត់សម្គាល់លើការពន្យល់ដែលផ្តល់ដោយប្រតិភូ គណៈកម្មាធិការនៅតែមានការព្រួយបារម្ភថាអ្នករងគ្រោះដោយសារគ្រឿងញៀនអាចត្រូវបានដកហូតសេរីភាព និងតម្រូវឱ្យទទួលនូវការស្តារនីតិសម្បទាដោយបង្ខំ ស្របតាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ គណៈកម្មាធិការក៏មានការព្រួយបារម្ភផងដែរថាជនដែលគ្មានទីលំនៅ អ្នកសុំទាន កុមារដែលរស់នៅតាមដងផ្លូវ និងជនមានពិការភាពផ្លូវចិត្ត ត្រូវបានឃុំខ្លួនដោយបំពាន និងបង្ខំឱ្យស្នាក់នៅក្នុងមជ្ឈមណ្ឌលសំចតសង្គមកិច្ច រាជធានីភ្នំពេញ (មណ្ឌលព្រៃស្ពឺ) ដែលប្រតិបត្តិការដោយពុំមានក្របខ័ណ្ឌបទប្បញ្ញត្តិច្បាស់លាស់ (មាត្រា ៩-១០)។

២៩. រដ្ឋភាគីគួរ ៖

(ក) បន្តការពិនិត្យឡើងវិញនូវច្បាប់ គោលនយោបាយ និងការអនុវត្តនានាដែលពាក់ព័ន្ធនឹងអ្នកប្រើគ្រឿងញៀន ជាពិសេសចំពោះបុគ្គលដែលត្រូវបានដកហូតសេរីភាពនៅក្នុងមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាគ្រឿងញៀន ក្នុងគោលបំណងនាំធ្វើឱ្យលិខិតបទដ្ឋានគតិយុត្ត និងការអនុវត្តទាំងនោះអនុលោមពេញលេញជាមួយនឹងកតិកាសញ្ញា។

(ខ) បញ្ចប់ការឃុំខ្លួនដោយមិនស្ម័គ្រចិត្ត ចំពោះជនអនាថា អ្នកសុំទាន និងជនមានពិការភាពផ្លូវចិត្តដែលត្រូវបានទុកឱ្យរស់នៅក្នុងមណ្ឌលសំចតឬមណ្ឌលស្តារនីតិសម្បទា និងចាត់វិធានការសមស្របដើម្បីផ្តល់ជម្រើសចំពោះការដាក់កុមាររស់នៅតាមដងផ្លូវក្នុងមណ្ឌល ដោយរួមបញ្ចូលការដាក់ពួកគេនៅក្នុងកន្លែងដែលមានលក្ខណៈបែបគ្រួសារ។

(គ) អនុម័តក្របខណ្ឌច្បាប់ច្បាស់លាស់ និងមានតម្លាភាព ដើម្បីធានាថាប្រព័ន្ធគាំទ្រសង្គមគ្រប់គ្រាន់ត្រូវបានផ្តល់ជូនប្រជាពលរដ្ឋដែលពិតជាត្រូវការជំនួយ រួមទាំងច្បាប់ស្តីពីការប្រព្រឹត្តិទៅនៃមណ្ឌលព្រៃស្ពឺ។

ការជួញដូរមនុស្ស

៣០. ទោះបីជាមានការខិតខំប្រឹងប្រែងជាច្រើនពីរដ្ឋភាគី ក្នុងការលុបបំបាត់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើកុមារក៏ដោយ គណៈកម្មាធិការនៅតែមានការព្រួយបារម្ភពីរបាយការណ៍អំពីកង្វះការការពារសម្រាប់ជនរងគ្រោះនៃការជួញដូរ ជាពិសេសស្ត្រី និងកុមារ។ គណៈកម្មាធិការក៏មានការព្រួយបារម្ភផងដែរអំពីករណីបញ្ចាំខ្លួនដោះបំណុលដោយរួមទាំងកុមារ ជាពិសេសនៅក្នុងឧស្សាហកម្មឥដ្ឋ (មាត្រា៨ និង២៦)។

**៣១. រដ្ឋភាគីគួរធានានូវប្រសិទ្ធិភាពនៃការពង្រឹងការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ រដ្ឋភាគីគួរធានាឱ្យបានថា គ្រប់ករណីជួញដូរមនុស្សទាំងអស់ត្រូវបានស៊ើបអង្កេតយ៉ាងលម្អិត ហើយបុគ្គលដែលទទួលខុសត្រូវលើករណីទាំងនោះនឹងត្រូវបានកាត់ទោស ហើយប្រសិនបើរកឃើញថាមានទោស ត្រូវទទួលរងការវិនិច្ឆ័យទោសសមស្រប ចំណែកជនរងគ្រោះត្រូវតែទទួលបានសំណងពេញលេញ ព្រមទាំងការការពារ និងជំនួយសមស្រប។ រដ្ឋភាគីគួរលុបបំបាត់នូវរាល់គ្រប់ទម្រង់នៃពលកម្មកុមារដោយបង្ខំ ជាពិសេសនៅតាមឧស្សាហកម្មឥដ្ឋ រួមទាំងពង្រឹងបន្ថែមនូវសមត្ថភាពរបស់បុគ្គលិកចុះអធិការកិច្ច ដើម្បីឱ្យពួកគាត់អាចអនុវត្តការងាររបស់ខ្លួនប្រកបដោយប្រសិទ្ធិភាព នៅក្នុងវិស័យដែលបញ្ហានេះកើតមានឡើងជាទូទៅ។**

ឯករាជ្យភាពនៃប្រព័ន្ធយុត្តិធម៌

៣២. បើទោះបីជាមានយន្តការមួយចំនួន ត្រូវបានអនុវត្តដោយរដ្ឋភាគីក្នុងការពង្រឹងឯករាជ្យភាពនៅក្នុងប្រព័ន្ធយុត្តិធម៌ក្តី ក៏គណៈកម្មាធិការនៅតែមានក្តីបារម្ភពីឯករាជ្យភាព និងភាពលំអៀងរបស់ប្រព័ន្ធយុត្តិធម៌ និងពីអត្រាខ្ពស់នៃការចោទប្រកាន់ពីភាពពុករលួយនៅក្នុងប្រព័ន្ធយុត្តិធម៌។ គណៈកម្មាធិការក៏បានកត់សម្គាល់ដោយក្តីបារម្ភចំពោះចៅក្រមមួយចំនួនដែលជាសមាជិកនៃគណបក្សកាន់អំណាច ដែលជាញឹកញាប់មានតួនាទីជាថ្នាក់ដឹកនាំ ហើយអាចធ្វើឱ្យប៉ះពាល់ដល់ឯករាជ្យភាពរបស់ពួកគាត់ (មាត្រា ១៤)។

**៣៣. រដ្ឋភាគីគួរអនុវត្តរាល់យន្តការទាំងផ្លូវច្បាប់ និងការអនុវត្ត ដើម្បីធានាបាននូវ ឯករាជ្យភាព មានមិនលំអៀង និងសុវត្ថិភាពរបស់អង្គចៅក្រម និងព្រះរាជអាជ្ញា។ រដ្ឋភាគីគួរមានយន្តការច្បាស់លាស់ដើម្បីរាំងមិនឱ្យចៅក្រមរងឥទ្ធិពលនយោបាយក្នុងការសម្រេចចិត្ត រួមទាំងការធានាឱ្យបាននូវដំណើរការជ្រើសរើស ការតែងតាំង ការផ្លាកតួនាទី ការបញ្ឈប់ និងការពិន័យទៅលើអង្គចៅក្រម និងព្រះរាជអាជ្ញា ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃកតិកាសញ្ញានេះ និងស្តង់ដារអន្តរជាតិដែលពាក់ព័ន្ធផ្សេងទៀត។**

សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ

៣៤. គណៈកម្មាធិការនៅតែបន្តមានក្តីបារម្ភ អំពីការរឹតត្បិតសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិដែលកើតមានជាបន្តបន្ទាប់នៅក្នុងរដ្ឋភាគី។ គណៈកម្មាធិការមានការភ្ញាក់ផ្អើល ពេលមានរបាយការណ៍ដែលបង្ហាញពីការបិទទីភ្នាក់ងារសារព័ត៌មានជាតិ និងអន្តរជាតិ ការបិទខ្ទប់គេហទំព័រដែលរិះគន់រដ្ឋាភិបាល ការប្រើប្រាស់ច្បាប់ព្រហ្មទណ្ឌ និងរដ្ឋប្បវេណីចំពោះអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ការរីករាលដាលនៃការបៀតបៀន និងការបំភិតបំភ័យទៅលើសកម្មជនអនឡាញ រួមបញ្ចូលទាំងអំឡុងពេលបោះឆ្នោត ឆ្នាំ២០១៨ និងដោយសារការរិះគន់រដ្ឋភាគីទៅលើយន្តការដោះស្រាយវិបត្តិកូវីដ១៩។ គណៈកម្មាធិការបានកត់សម្គាល់ដោយក្តីបារម្ភចំពោះ

បទចោទប្រកាន់ព្រហ្មទណ្ឌមួយចំនួនស្ថិតក្នុងក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីទូរគមនាគមន៍ រួមទាំងការបរិហារកេរ្តិ៍ ការញុះញង់ ការប្រមាថ និងការប្រមាថព្រះមហាក្សត្រ ដែលជាញឹកញាប់ត្រូវបានប្រើដើម្បីរឹតត្បិតដោយមិនសមស្របឬហួសហេតុ ទៅលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ មិនតែប៉ុណ្ណោះ គណៈកម្មាធិការបារម្ភពីអនុក្រឹតស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ និងសេចក្តីព្រាងច្បាប់ថ្មីៗ រួមទាំងសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន និងការទទួលបានព័ត៌មាន និងវិសោធនកម្មច្បាប់ស្តីពីរបបសារព័ត៌មាន ដែលបានបង្កក្តីបារម្ភយ៉ាងខ្លាំងចំពោះការរឹតត្បិតកាន់តែធ្ងន់ធ្ងរទៅលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងដែលត្រូវបានរៀបចំឡើងដោយមិនមានការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល និងភាគីពាក់ពន្ធនានា (មាត្រា១៩)។

៣៥. គណៈកម្មាធិការ សូមបញ្ជាក់ឡើងវិញអំពីអនុសាសន៍កន្លងមកស្តីពីសេរីភាពនៃការបញ្ចេញមតិ និងជំរុញរដ្ឋភាគីចាត់វិធានការបន្ទាន់ដើម្បីធានាថាជនគ្រប់រូបអាចប្រើប្រាស់សិទ្ធិដោយសេរីក្នុងការបញ្ចេញមតិ ដោយយោងតាមមាត្រា១៩ នៃកតិកាសញ្ញា និងសេចក្តីពន្យល់ទូទៅរបស់គណៈកម្មាធិការ លេខ៣៤ (២០១១) ស្តីពីសេរីភាពនៃគំនិត និងការសម្តែងមតិ។ ដើម្បីធ្វើដូចនេះបាន រដ្ឋភាគីត្រូវ៖

(ក) ជៀសវាងការផ្តន្ទាទោស និងដាក់ពន្ធនាគារអ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស និងតួអង្គសង្គមស៊ីវិលផ្សេងទៀត ដែលការផ្តន្ទាទោស និងដាក់ពន្ធនាគារជាមធ្យោបាយរារាំង ឬបំបាក់ទឹកចិត្តក្រុមទាំងនោះពីការបញ្ចេញមតិយោបល់ដោយសេរី។

(ខ) បង្ការរាល់សកម្មភាពឃាយី និងការគំរាមកំហែង ការរឹតបន្តឹងតាមទំនើងចិត្ត ការចាប់ខ្លួនអ្នកសារព័ត៌មាន សកម្មជន និងអ្នកការពារសិទ្ធិមនុស្ស ដែលគ្រាន់តែរិះគន់មន្ត្រីសាធារណៈ ឬគោលនយោបាយរាជរដ្ឋាភិបាល។

(គ) លុបបទការបរិហារកេរ្តិ៍ចេញពីបទល្មើសព្រហ្មទណ្ឌ និងរាល់បទប្បញ្ញត្តិទាក់ទងនៅក្នុងក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីទូរគមនាគមន៍ ឱ្យស្របនឹងមាត្រា១៩ នៃកតិកាសញ្ញា។

(ឃ) ពិនិត្យឡើងវិញ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តបច្ចុប្បន្នដែលកំពុងរងចាំការអនុម័ត រួមមានអនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ សេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីរបបសារព័ត៌មាន និងសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន និងសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន ដើម្បីជៀសវាងការប្រើវាក្យស័ព្ទមិនច្បាស់លាស់ និងការរឹតត្បិតទូលំទូលាយ។

(ង) ធានាថារាល់ការតាក់តែង និងការអនុវត្តលិខិតបទដ្ឋានគតិយុត្តនានា រួមទាំងប្រកាសក្រសួង រាល់ការដាក់កំហិតលើការអនុវត្តសេរីភាពនៃការបញ្ចេញមតិ និងការជួបប្រជុំ ត្រូវអនុលោមតាមតម្រូវការដ៏តឹងរឹងនៃមាត្រា ១៩ (៣) និងមាត្រា ២២ នៃកតិកាសញ្ញានេះ។

សិទ្ធិជួបជុំដោយសន្តិវិធី និងសេរីភាពនៃសមាគម

៣៦. គណៈកម្មាធិការព្រួយបារម្ភយ៉ាងខ្លាំង អំពីរបាយការណ៍នៃការបដិសេធក្នុងការអនុញ្ញាតឱ្យមានជួបប្រជុំដោយសន្តិវិធីដោយមិនសមហេតុផល និងការចាប់ខ្លួនអ្នករៀបចំផ្អែកលើបទប្បញ្ញត្តិច្បាប់មិនច្បាស់លាស់ដែលមានចែងក្នុងច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។ គណៈកម្មាធិការព្រួយបារម្ភយ៉ាងខ្លាំងចំពោះព័ត៌មានដែលទទួលបានអំពីការប្រើប្រាស់កម្លាំងលើសលុប និងមិនសមាមាត្រ ដើម្បីបំបែកការធ្វើបាតុកម្មដោយសន្តិវិធី

ដែលនាំឱ្យមានការចាប់ខ្លួន និងការឃុំខ្លួនបាតុករជាច្រើន រួមមាន អ្នកការពារសិទ្ធិមនុស្ស សកម្មជនបរិស្ថាន ថ្នាក់ដឹកនាំបក្សប្រឆាំង និងសមាជិកសហជីព (ដូចជា អ្នកទាក់ទងនឹងដែនជម្រកសត្វព្រៃ ព្រៃឡង់ មាតាធម្មជាតិកម្ពុជា សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍)។ គណៈកម្មាធិការ ក៏បានកត់សម្គាល់ដោយក្ដីកង្វល់លើការធ្វើវិសោធនកម្មច្បាប់សហជីព នៅខែមករា ឆ្នាំ២០២០ និងសេចក្ដីព្រាងច្បាប់ស្ដីពីសណ្ដាប់ធ្នាប់សាធារណៈ ដែលមានគោលដៅគ្រប់គ្រងការចូលប្រើប្រាស់ និងអាកប្បកិរិយានៅទីធ្លាសាធារណៈ អាចរហូតដល់កំហិតសិទ្ធិនៃការជួបជុំដោយសន្តិវិធី ដោយសារតែពីច្បាប់ទាំងពីរពុំបានផ្ដល់នូវនិយមន័យដល់ពាក្យពេចន៍មួយចំនួនឱ្យបានច្បាស់លាស់ ដែលនោះអាចធ្វើឱ្យអាជ្ញាធរបកស្រាយ និងប្រើប្រាស់ច្បាប់នេះខុសពីគោលបំណងដើម។ បន្ថែមលើនេះទៀត គណៈកម្មាធិការក៏បានធ្វើការកត់សម្គាល់ដោយការព្រួយបារម្ភថាច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល បានដាក់កាតព្វកិច្ចឱ្យអង្គការនានាផ្ដល់របាយការណ៍មិនសមហេតុផល ដែលនាំឱ្យមានការបដិសេធការចុះបញ្ជី និងការឈ្លបមើលអ្នកការពារសិទ្ធិមនុស្ស (មាត្រា ២១-២២)។

**៣៧. យោងតាមមាត្រា២១ នៃកតិកាសញ្ញា និងសេចក្ដីពន្យល់ទូទៅលេខ៣៧ (២០២០) របស់គណៈកម្មាធិការ ស្ដីពីសិទ្ធិជួបជុំដោយសន្តិវិធី រដ្ឋភាគីគួរ ៖**

**(ក) ពន្លឿនការខិតខំប្រឹងប្រែងដើម្បីពិនិត្យឡើងវិញនូវលិខិតបទដ្ឋានគតិយុត្តបច្ចុប្បន្ន ដែលកំពុងរងចាំការអនុម័ត រួមមាន វិសោធនកម្មលើច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងសេចក្ដីព្រាងច្បាប់ស្ដីពីសណ្ដាប់ធ្នាប់សាធារណៈ ក៏ដូចជាការអនុវត្តជាក់ស្ដែង ដើម្បីធានាថាបុគ្គលគ្រប់រូបអាចប្រើប្រាស់សិទ្ធិជួបជុំដោយសន្តិវិធីពេញលេញទាំងនៅក្នុងច្បាប់ និងការអនុវត្ត និងដើម្បីធានាថាមានការពិគ្រោះយោបល់លើការពិនិត្យឡើងវិញទាំងអស់ ប្រកបដោយអត្ថន័យ បើកចំហ និងតម្លាភាពជាមួយអង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សេងទៀត។**

**(ខ) ធានាថាការរឹតត្បិតណាមួយលើសិទ្ធិនៃការជួបជុំដោយសន្តិវិធី រួមទាំងតាមរយៈការអនុវត្តការដាក់ទណ្ឌកម្មផ្នែករដ្ឋបាល និងព្រហ្មទណ្ឌប្រឆាំងនឹងបុគ្គលដែលអនុវត្តសិទ្ធិនោះ ត្រូវអនុលោមតាមតម្រូវការដ៏តឹងរឹងនៃមាត្រា ២១ នៃកតិកាសញ្ញា**

**(គ) ស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាពរាល់ករណីនៃការចាប់ខ្លួន និងឃុំខ្លួនដោយអំពើចិត្ត លើអ្នកតវ៉ាដោយសន្តិវិធី ក៏ដូចជាអំពើហិង្សាលើពួកគេ ហើយនាំអ្នកទទួលខុសត្រូវមកកាត់ទោស**

**(ឃ) ទប់ស្កាត់រាល់ទម្រង់នៃការយាយី និងការបំភិតបំភ័យសមាជិកអង្គការសង្គមស៊ីវិល សហជីព និងគណបក្សនយោបាយ និងធានាថាពួកគេអាចអនុវត្តសិទ្ធិការងារ និងសកម្មភាពពាក់ព័ន្ធដោយសេរី។**

ការចូលរួមក្នុងកិច្ចការសាធារណៈ

៣៨. គណៈកម្មាធិការមានការព្រួយបារម្ភអំពីការរំលាយគណបក្សនយោបាយប្រឆាំងធំ គឺគណបក្សសង្គ្រោះជាតិ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ និងគណបក្សប្រឆាំងចំនួនបីផ្សេងទៀតនៅឆ្នាំ២០២១ និងការផ្ទេរអាសនៈទាំងអស់របស់គណបក្សសង្គ្រោះជាតិនៅក្នុងរដ្ឋសភាទៅឱ្យគណបក្សកាន់អំណាច គឺគណបក្សប្រជាជនកម្ពុជា ដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះបោះឆ្នោត។ គណៈកម្មាធិការមានការព្រួយបារម្ភអំពីឯករាជ្យភាព និងភាពមិនលំអៀងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងការលំបាកដែលគណបក្ស

ថ្មីត្រូវប្រឈមក្នុងការធ្វើយុទ្ធនាការឃោសនាបោះឆ្នោតដែលស្មើភាព ដោយសេរី និងតម្លាភាព។ គណៈកម្មាធិការសម្តែងការព្រួយបារម្ភយ៉ាងខ្លាំង ចំពោះការដាក់កំហិតមិនស្របច្បាប់មកលើសមាជិកគណបក្សប្រឆាំងទាក់ទងនឹងការចូលរួមរបស់ពួកគេក្នុងកិច្ចការសាធារណៈ និងការបោះឆ្នោត តាមរយៈការគំរាមកំហែង ការយាយី ការចាប់ខ្លួនតាមអំពើចិត្ត ការជំនុំជម្រះក្តីទ្រង់ទ្រាយធំ ការដកហូតលិខិតឆ្លងដែន និងអំពើហិង្សា ដូចជាការសម្លាប់សមាជិកគណបក្សសង្គ្រោះជាតិ គឺលោក ស៊ិន ខុន កាលពីខែវិច្ឆិកា ឆ្នាំ២០២១ (មាត្រា ២, ៦ និង ២៥)។

៣៩. រដ្ឋភាគីគួរធ្វើឱ្យបទប្បញ្ញត្តិ និងការអនុវត្តជុំវិញការបោះឆ្នោត អនុលោមយ៉ាងពេញលេញតាមកតិកាសញ្ញា រួមមានមាត្រា ២៥ ដោយវិធីខាងក្រោម ៖

(ក) បញ្ចប់ការចាប់ខ្លួនតាមអំពើចិត្ត និងអំពើយាយី ការបំភិតបំភ័យ និងអំពើហិង្សាលើសមាជិក និងអ្នកគាំទ្រគណបក្សប្រឆាំង

(ខ) ធ្វើការស៊ើបអង្កេតឱ្យបានហ្មត់ចត់ និងឯករាជ្យលើរាល់ការចោទប្រកាន់ពីការយាយី ការបំភិតបំភ័យ និងការចាប់ខ្លួនតាមអំពើចិត្ត និងអំពើហិង្សាលើសមាជិក និងអ្នកគាំទ្រគណបក្សប្រឆាំង ជាពិសេសក្នុងការសម្លាប់លោក ស៊ិន ខុន និងនាំជនល្មើសមកកាត់ទោស

(គ) បញ្ចប់ការជំនុំជម្រះក្តីទ្រង់ទ្រាយធំទាំងអស់ប្រឆាំងនឹងសមាជិកនៃគណបក្សប្រឆាំង និងធានាថាដំណើរការទាំងអស់ដែលបានធ្វើឡើងប្រឆាំងនឹងពួកគេ ក៏ដូចជាប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្ស គឺស្របតាមការធានាផ្នែកនីតិវិធីទាំងអស់ដែលមានចែងក្នុងកតិកាសញ្ញា

(ឃ) ធានានូវការប្រើប្រាស់សិទ្ធិបោះឆ្នោតដោយជនគ្រប់រូប ដោយពេញលេញ និងប្រកបដោយអត្ថន័យ រួមទាំងបេក្ខជននយោបាយរបស់គណបក្សប្រឆាំង និងគណបក្សនយោបាយទាំងអស់អាចធ្វើយុទ្ធនាការបោះឆ្នោតដោយស្មើភាព សេរី និងតម្លាភាព

(ង) ធានានូវសេរីភាពក្នុងការចូលរួមក្នុងការជជែកដេញដោលនយោបាយពហុនិយម រួមទាំងសម្របសម្រួលការធ្វើបាតុកម្ម និងកិច្ចប្រជុំដោយសន្តិវិធី និងជៀសវាងពីការប្រើប្រាស់ច្បាប់ព្រហ្មទណ្ឌ ដើម្បីគាបសង្កត់សេរីភាព ឬដើម្បីដកចេញបេក្ខជនប្រឆាំងពីដំណើរការបោះឆ្នោត

(ច) ពង្រឹងយន្តការតុលាការ និងការបោះឆ្នោត ដើម្បីធានាដំណើរការបោះឆ្នោតដោយយុត្តិធម៌ ជាពិសេសដើម្បីឱ្យទាន់ពេលវេលាសម្រាប់ការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០២២ និងការបោះឆ្នោតជាតិឆ្នាំ២០២៣។

យុត្តិធម៌អនីតិជន

៤០. ខណៈដែលគណៈកម្មាធិការស្វាគមន៍ការអនុម័តច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ ២០១៦ គណៈកម្មាធិការមានការសោកស្តាយ ដែលការអនុវត្តច្បាប់នេះនៅមានកម្រិត ហើយក្នុងការអនុវត្តជាក់ស្តែង កុមារដែលមានទំនាស់នឹងច្បាប់នៅតែបន្តដាក់ឱ្យនៅក្នុងការឃុំឃាំងបណ្តោះអាសន្ន។ គណៈកម្មាធិការក៏មានការព្រួយបារម្ភអំពីការផ្ទេរកុមារមកពីខេត្តដាច់ស្រយាល ដែលពួកគេពឹងផ្អែកលើជំនួយសម្ភារៈ និងការគាំទ្រផ្នែកផ្លូវចិត្តរបស់គ្រួសារពួកគេ ទៅកាន់កន្លែងថ្មី មណ្ឌលយុវនីតិសម្បទា នៅខេត្តកណ្តាលសម្រាប់ការឃុំខ្លួន (មាត្រា ២៣-២៤)។

៤១. រដ្ឋភាគីគួរពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីធានាការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជនប្រកបដោយប្រសិទ្ធភាព និងធានាថាកុមារដែលមានទំនាស់នឹងច្បាប់ត្រូវបានប្រព្រឹត្តិតាមរបៀបដែលសមស្របនឹងអាយុរបស់ពួកគេ។ រដ្ឋភាគីក៏គួរតែធានាថា ការឃុំខ្លួនអនីតិជនបណ្តោះអាសន្នគួរតែត្រូវបានប្រើយ៉ាងតឹងរឹង នៅក្នុងករណីពិសេស និងត្រូវប្រើតែជាជម្រើសចុងក្រោយប៉ុណ្ណោះ។ រដ្ឋភាគីគួរតែពិចារណាលើការពិនិត្យឡើងវិញឱ្យបានហ្មត់ចត់ ដើម្បីវាយតម្លៃលើជម្រើសផ្សេងទៀតជាជាងការឃុំខ្លួន លើករណីកុមារដែលមានទំនាស់នឹងច្បាប់ដែលនឹងត្រូវផ្ទេរទៅមណ្ឌលយុវនីតិសម្បទា ។

ជនជាតិដើមភាគតិច

៤២. គណៈកម្មាធិការស្វាគមន៍ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋភាគី ក្នុងការពង្រឹងយន្តការការពារសិទ្ធិជនជាតិដើមភាគតិច។ ទោះជាយ៉ាងណាក៏ដោយ គណៈកម្មាធិការនៅតែមានការព្រួយបារម្ភចំពោះចំណុចខ្វះខាតក្នុងការអនុវត្តក្របខ័ណ្ឌច្បាប់ និងការការពារសិទ្ធិជនជាតិដើមភាគតិចក្នុងការប្រើប្រាស់ និងកាន់កាប់ដីធ្លី និងទឹកដីរបស់ពួកគេ។ គណៈកម្មាធិការមានការព្រួយបារម្ភថាពុំមានការគោរពជាប្រព័ន្ធលើ សិទ្ធិរបស់ជនជាតិដើមភាគតិច ក្នុងការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ នៅក្នុងដំណើរការធ្វើការសម្រេចចិត្តដែលប៉ះពាល់ដល់ពួកគេ និងជាពិសេសក្នុងការផ្តល់ការយល់ព្រមលើគម្រោងអភិវឌ្ឍន៍លើដីរបស់ពួកគេ ។ គណៈកម្មាធិការក៏សម្តែងការព្រួយបារម្ភរបស់ខ្លួនអំពីការការពារប្រកបដោយប្រសិទ្ធភាពចំពោះសហគមន៍ជនជាតិដើមភាគតិចក្នុងបរិបទនៃការរាតត្បាតនៃមេរោគកូវីដ-១៩ (មាត្រា ២ និង ២៦-២៧)។

៤៣. រដ្ឋភាគីគួរ ៖

(ក) បង្កើត និងអនុម័តក្របខ័ណ្ឌច្បាប់ ដើម្បីទទួលស្គាល់ និងការពារសិទ្ធិជនជាតិដើមភាគតិច រួមទាំងនីតិវិធីសាមញ្ញសម្រាប់ការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព។

(ខ) ធានាឱ្យបាននូវការពិគ្រោះយោបល់ពេញលេញ និងប្រកបដោយអត្ថន័យជាមួយជនជាតិដើមភាគតិច ក្នុងបញ្ហាទាក់ទងនឹងសិទ្ធិរបស់ពួកគេ ជាពិសេសសិទ្ធិក្នុងការយល់ព្រមជាមុន ដោយសេរី បន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ រួមទាំងនៅពេលផ្តល់ការអនុញ្ញាតលើគម្រោងអភិវឌ្ឍន៍ដែលអាចប៉ះពាល់ដល់សិទ្ធិដីធ្លីរបស់ពួកគេ

(គ) បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការទប់ស្កាត់ជម្លោះលើការប្រើប្រាស់ដីធ្លី រួមទាំងផ្តល់ការធានាទាក់ទងនឹងដីដែលជនជាតិដើមភាគតិចកាន់កាប់ ឬជាម្ចាស់កម្មសិទ្ធិប្រពៃណី ។

(ឃ) ធានាថាជនជាតិដើមភាគតិចមិនត្រូវបានផ្លាស់ប្តូរទីលំនៅដោយមិនអនុវត្តតាមការការពារផ្លូវច្បាប់ និងនីតិវិធីទាំងអស់ រួមទាំងការផ្តល់ជម្រើសទទួលសំណងដែលគ្រប់គ្រាន់ និងមានជម្រើសអាចប្រៀបធៀបបាន។

(ង) ត្រូវប្រាកដថាក្នុងបរិបទនៃការរាតត្បាតនៃជំងឺកូវីដ-១៩ ជនជាតិដើមភាគតិចមានសិទ្ធិទទួលបានព័ត៌មាន និងសេវាថែទាំសុខភាព រួមទាំងការធ្វើតេស្ត ការព្យាបាល និងការទទួលបានវ៉ាក់សាំង។

**ឃ. ការផ្សព្វផ្សាយ និងការតាមដាន**

៤៤. រដ្ឋភាគីគួរផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវកតិកាសញ្ញា របាយការណ៍តាមកាលកំណត់ ជុំទីបី របស់ខ្លួន និងការសង្កេតសន្និដ្ឋានបច្ចុប្បន្ន ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិ ដែលមានចែងក្នុងកតិកាសញ្ញា ក្នុងចំណោមអាជ្ញាធរតុលាការ នីតិប្បញ្ញត្តិ និងរដ្ឋបាល សង្គមស៊ីវិល និងអង្គការក្រៅរដ្ឋាភិបាល ដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេស ព្រមទាំងប្រជាជនទូទៅផងដែរ។ រដ្ឋភាគីគួរធានាថារបាយការណ៍តាមកាលកំណត់ និងការសង្កេតសន្និដ្ឋានបច្ចុប្បន្ន ត្រូវបានបកប្រែទៅជាភាសាផ្លូវការរបស់រដ្ឋភាគី។

៤៥. អនុលោមតាមវិធាន ៧៥ (១) នៃវិធាននីតិវិធីរបស់គណៈកម្មាធិការ រដ្ឋភាគីត្រូវបានស្នើសុំឱ្យផ្តល់នៅត្រឹមថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៥ នូវព័ត៌មានស្តីពីការអនុវត្តអនុសាសន៍ ដែលធ្វើឡើងដោយគណៈកម្មាធិការក្នុងកថាខណ្ឌទី៩ (អំពើពុករលួយ) កថាខណ្ឌទី៣៥ (សេរីភាពនៃការបញ្ចេញមតិ) និងកថាខណ្ឌទី៣៩ (ការចូលរួមនយោបាយ) ខាងលើ។

៤៦. ស្របតាមវដ្តនៃការត្រួតពិនិត្យដែលអាចព្យាករណ៍បានរបស់គណៈកម្មាធិការ នៅឆ្នាំ២០២៨ មុនពេលដាក់របាយការណ៍ រដ្ឋភាគីនឹងទទួលបាននូវបញ្ជីបញ្ហារបស់គណៈកម្មាធិការ និងក្នុងរយៈពេលមួយឆ្នាំ រដ្ឋភាគីត្រូវបានរំពឹងថានឹងដាក់ជូនការឆ្លើយតបរបស់ខ្លួនចំពោះបញ្ជីបញ្ហា ដែលនេះនឹងបង្កើតបានជារបាយការណ៍តាមកាលកំណត់ជុំទីបួនរបស់ខ្លួន។ ក្នុងការរៀបចំរបាយការណ៍នេះ គណៈកម្មាធិការក៏ស្នើឱ្យរដ្ឋភាគី ពិគ្រោះយោបល់ឱ្យបានទូលំទូលាយជាមួយសង្គមស៊ីវិល និងអង្គការក្រៅរដ្ឋាភិបាល ដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេស។ យោងតាមសេចក្តីសម្រេចរបស់មហាសន្និបាតលេខ៦៨/២៦៨ ចំនួនកំណត់ពាក្យសម្រាប់របាយការណ៍គឺ ២១ ២០០ ពាក្យ។ ការសន្ទនាក្នុងន័យស្ថាបនាជាមួយរដ្ឋភាគី នឹងប្រព្រឹត្តទៅនៅឆ្នាំ២០៣០ នៅទីក្រុងហ្សឺណែវ។